លេខ ១៨ ចេញផ្សាយថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២២

# ព្រឹត្តិបត្រព័ត៌មានប្រចាំខែវិច្ឆិកា ឆ្នាំ២០២២

**និយ័តករបរធនបាលកិច្ច**
**គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ**
**បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា**

## មាតិកា


- ប្រជុំលើកទី ១ របស់គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល (**គ.ស.ធ.ឌ.**) ទំព័រទី១
- កិច្ចប្រជុំអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ. ស. ហ.) ទំព័រទី២
- កិច្ចប្រជុំបូកសរុបការងារប្រចាំខែតុលា ឆ្នាំ២០២២ របស់នាយកដ្ឋានកិច្ចការទូទៅ ទំព័រទី២
- កិច្ចប្រជុំបូកសរុបការងារប្រចាំខែតុលា ព្រមទាំងទិសដៅការងារប្រចាំខែវិច្ឆិកា ឆ្នាំ២០២២ ទំព័រទី២
- កិច្ចជំជួបពិភាក្សាជាមួយ Nanyang Business School នៃ Nanyang Technological University ប្រទេសសិង្ហបុរី ទំព័រទី៣
- កិច្ចប្រជុំអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ទំព័រទី៣
- សិក្ខាសាលាផ្សព្វផ្សាយស្ដីពីការដាក់ឱ្យអនុវត្តប្រកាសស្ដីពី “ការទទួលស្គាល់ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច” ទំព័រទី៤
- កិច្ចប្រជុំ លើកទី៥ របស់គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ទំព័រទី៤
- វគ្គបណ្ដុះបណ្ដាលស្ដីពី “ការត្រួតពិនិត្យផ្ទៃក្នុង, ការរាយការណ៍ និងកាតព្វកិច្ចពាក់ព័ន្ធរបស់បុគ្គលរាយការណ៍ ក្នុងក្របខណ្ឌការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ” ទំព័រទី៥
- កិច្ចប្រជុំអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ទំព័រទី៥
- ប្រជុំស្ដីពីការផ្សព្វផ្សាយអំពីគម្រោង ACSEP នៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តត្បូងឃ្មុំ ទំព័រទី៦
- កិច្ចប្រជុំដើម្បីត្រៀមលក្ខណៈសម្រាប់ការចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ក្រុមការងារ ICRG-JG ក្នុងការដកប្រទេសកម្ពុជាចេញពីបញ្ជីប្រផេះ ទំព័រទី៦


## ប្រជុំលើកទី ១ របស់គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល (គ.ស.ធ.ឌ.)

នៅព្រឹកថ្ងៃពុធ ៩កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២២ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាសមាជិកគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល បានចូលរួមកិច្ចប្រជុំលើកទី១ របស់គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល (**គ.ស.ធ.ឌ.**) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន **គ.ស.ធ.ឌ.** តាមរយៈប្រព័ន្ធសន្និសីទវីឌីអូពីចំងាយ (Zoom)។

កិច្ចប្រជុំនេះ មានការចូលរួមពី ឯកឧត្តមរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ឯកឧត្តម លោកជំទាវ រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី រដ្ឋលេខាធិការ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាល អគ្គនាយកតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ និងជាសមាជិក-សមាជិកា **គ.ស.ធ.ឌ.**។




រូបភាពប្រជុំលើកទី១ របស់គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល (គ.ស.ធ.ឌ.) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## កិច្ចប្រជុំអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)

នារសៀលថ្ងៃពុធ ៩កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២២ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយកញ្ញា **ឈាន សុខារី** ប្រធាននាយដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច បានចូលរួមកិច្ចប្រជុំអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដើម្បីពិនិត្យទៅលើរបៀបវារៈចំនួនពីរ រួមមានៈ សេចក្តីព្រាងអនុក្រឹត្យស្តីពី "គោលការណ៍ណែនាំសម្រាប់ការវិនិយោគមូលនិធិសន្តិសុខសង្គម" និងសេចក្តីព្រាងប្រកាសស្តីពីការដោះស្រាយវិវាទក្នុងប្រព័ន្ធសន្តិសុខសង្គម" របស់និយ័តករសន្តិសុខសង្គម ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សានៃ **អ.ស.ហ.** ដោយមានការចូលរួមពីឯកឧត្តមអគ្គនាយកថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃនិយ័តករ និងអង្គភាពក្រោមឱវាទនៃ **អ.ស.ហ.** តាមរយៈកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាននៃ **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ Zoom។




រូបភាពកិច្ចប្រជុំអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.) ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **រស់ សីលវ៉ា**។

## កិច្ចប្រជុំបូកសរុបការងារប្រចាំខែតុលា ឆ្នាំ២០២២ របស់នាយកដ្ឋានកិច្ចការទូទៅ

នារសៀលថ្ងៃព្រហស្បតិ៍ ១០កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២២ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **ឯកឧត្តម ណី សាគល** អគ្គនាយករងនៃ **ន.ប.ធ.** បានដឹកនាំកិច្ចប្រជុំបូកសរុបការងារប្រចាំខែតុលា ឆ្នាំ២០២២ របស់នាយកដ្ឋានកិច្ចការទូទៅ។

កិច្ចប្រជុំនេះ មានការចូលរួមពីប្រធាននាយកដ្ឋាន, ប្រធានការិយាល័យ, អនុប្រធានការិយាល័យ និងមន្ត្រីជំនាញនៃនាយកដ្ឋាន។

ជាមួយគ្នានេះ ឯកឧត្តមអគ្គនាយករងបានធ្វើការវាយតម្លៃខ្ពស់លើសមិទ្ធផលការងារដែលសម្រេចបានក្នុងខែតុលា ឆ្នាំ២០២២ ព្រមទាំងបានកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែង និងការទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់នៃនាយកដ្ឋាន និងបានផ្តល់ជាអនុសាសន៍ណែនាំសម្រាប់ទិសដៅការងារបន្តផងដែរ។



រូបភាពកិច្ចប្រជុំបូកសរុបការងារប្រចាំខែតុលា ឆ្នាំ២០២២ របស់នាយកដ្ឋានកិច្ចការទូទៅ ដឹកនាំដោយ **ឯកឧត្តម ណី សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច។

## កិច្ចប្រជុំបូកសរុបការងារប្រចាំខែតុលា ព្រមទាំងទិសដៅការងារប្រចាំខែវិច្ឆិកា ឆ្នាំ២០២២

នាព្រឹកថ្ងៃសុក្រ ១១កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២២ **ឯកឧត្តម នង ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំកិច្ចប្រជុំបូកសរុបការងារប្រចាំខែតុលា ព្រមទាំងទិសដៅការងារប្រចាំខែវិច្ឆិកា ឆ្នាំ២០២២ ក្នុងកម្រិតអន្តរនាយកដ្ឋាន រួមមាននាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច និងនាយកដ្ឋានស្រាវជ្រាវបណ្តុះបណ្តាល និងសហប្រតិបត្តិការ។ កិច្ចប្រជុំនេះ មានការចូលរួមពីប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន, ប្រធានការិយាល័យ, អនុប្រធានការិយាល័យនិងមន្ត្រីជំនាញទាំងអស់នៃនាយកដ្ឋានទាំងពីរ។ នៅក្នុងកិច្ចប្រជុំនេះ ឯកឧត្តមអគ្គនាយករងបានធ្វើការវាយតម្លៃខ្ពស់លើសមិទ្ធផលការងារដែលសម្រេចបានក្នុងខែតុលា ព្រមទាំងបានកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែង និងការទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់នៃនាយកដ្ឋានទាំងពីរ និងបានផ្តល់ជាអនុសាសន៍ណែនាំសម្រាប់ទិសដៅការងារនៅក្នុងខែបន្ទាប់ផងដែរ។ កិច្ចប្រជុំនេះ បានបញ្ចប់ដោយរលូនប្រកបដោយផ្លែផ្កា និងស្មារតីទទួលខុសត្រូវខ្ពស់។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888



រូបភាពកិច្ចប្រជុំបូកសរុបការងារប្រចាំខែតុលា ព្រមទាំងទិសដៅការងារប្រចាំខែវិច្ឆិកា ឆ្នាំ២០២២ ដឹកនាំដោយ ឯកឧត្តម នង ពិសិដ្ឋ អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (ន.ប.ធ.) ។

## កិច្ចជំជួបពិភាក្សាជាមួយ Nanyang Business School នៃ Nanyang Technological University ប្រទេសសិង្ហបុរី

នាព្រឹកថ្ងៃសុក្រ ១១កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២២ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី ឯកឧត្តម សុខ ដារ៉ា អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **ឯកឧត្តម ណី សាកល** អគ្គនាយករងនៃ **ន.ប.ធ.** អមដោយ **លោក ប៉ូ សំអាង** ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ និងមន្ត្រីជំនាញនៃ **ន.ប.ធ.** បានទទួលជួបប្រជុំពិភាក្សាជាមួយ Nanyang Business School នៃ Nanyang Technological University ប្រទេសសិង្ហបុរី តំណាងដោយ លោក Eugene Leong អនុប្រធាន Nanyang Business School ដើម្បីចែករំលែកព័ត៌មានអំពីកម្មវិធីអាហារូបករណ៍ផ្តល់ដោយ Nanyang Business school ដល់មន្ត្រីជាន់ខ្ពស់នៃ **ន.ប.ធ.** តាមប្រព័ន្ធវីដេអូ។ កិច្ចជំនួបនេះបានបញ្ចប់ទៅ ដោយភាពរលូន និងប្រកបដោយផ្លែផ្កា ។




រូបភាពកិច្ចជំជួបពិភាក្សាជាមួយ Nanyang Business School នៃ Nanyang Technological University ប្រទេសសិង្ហបុរី។

## កិច្ចប្រជុំអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)

នារសៀលថ្ងៃសុក្រ ១១កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២២ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយកញ្ញា **ឈាន សុខារី** ប្រធាននាយដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច និងមន្ត្រីបច្ចេកទេសនៃ **ន.ប.ធ.** បានចូលរួមកិច្ចប្រជុំអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដើម្បីពិនិត្យទៅលើរបៀបវារៈចំនួន បួន រួមមាន៖ (១).សេចក្តីព្រាងប្រកាសស្តីពី "ការដោះស្រាយវិវាទក្នុងប្រព័ន្ធសន្តិសុខសង្គម" របស់និយ័តករសន្តិសុខសង្គម, (២).សេចក្តីព្រាងប្រកាសស្តីពីកាតព្វកិច្ចផ្តល់របាយការណ៍ជូនដំណឹងនិងការស្នើសុំការអនុញ្ញាតរបស់ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស, (៣).សេចក្តីព្រាងប្រកាសស្តីពីកាតព្វកិច្ចផ្តល់របាយការណ៍ជូនដំណឹងនិងការស្នើសុំការអនុញ្ញាតរបស់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ និង (៤).សេចក្តីព្រាងប្រកាសស្តីពីកាតព្វកិច្ចផ្តល់របាយការណ៍ជូនដំណឹងនិងការស្នើសុំការអនុញ្ញាតរបស់ក្រុមហ៊ុនចែកចាយលក់ទិញត្រឡប់មកវិញឬទូទាត់សង ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សានៃ **អ.ស.ហ.** ដោយមានការចូលរួមពីឯកឧត្តមអគ្គនាយក ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃនិយ័តករ និងអង្គភាពក្រោមឱវាទនៃ **អ.ស.ហ.** តាមរយៈកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាននៃ **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ Zoom។




រូបភាពកិច្ចប្រជុំអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.) ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **រស់ សីលវ៉ា** ។

## សិក្ខាសាលាផ្សព្វផ្សាយស្ដីពីការដាក់ឱ្យអនុវត្តប្រកាសស្ដីពី "ការទទួលស្គាល់ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច"

នៅព្រឹកថ្ងៃអង្គារ ៧រោច ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្ដីពីការដាក់ឱ្យអនុវត្តប្រកាសស្ដីពី "ការទទួលស្គាល់ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច" នៅទីស្ដីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដាវ៉ា** អគ្គនាយកនៃ **ន.ប.ធ.**។

សិក្ខាសាលានេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងបញ្ជ្រាបការយល់ដឹងបន្ថែមដល់សិក្ខាកាមទាំងអស់អំពីលក្ខខណ្ឌ និងនីតិវិធីនៃការទទួលស្គាល់ក្រុមហ៊ុនវាយតម្លៃ និងអ្នកជំនាញវាយតម្លៃអចលនវត្ថុក្នុងវិស័យបរធនបាលកិច្ច ក៏ដូចជាសិទ្ធិ និងកាតព្វកិច្ចរបស់ក្រុមហ៊ុនវាយតម្លៃ និងអ្នកជំនាញវាយតម្លៃ សំដៅធានាឱ្យបាននូវសុក្រឹតភាពនៃតម្លៃបរធនបាលកិច្ចដែលបានបង្កើត និងចុះបញ្ជីបរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា។

សិក្ខាសាលានេះ មានការអញ្ជើញចូលរួមពីតំណាងនិយ័តករពាក់ព័ន្ធក្រោមឱវាទ **អ.ស.ហ.** ថ្នាក់ដឹកនាំ និងសមាជិក-សមាជិកា សមាគមអ្នកវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុកម្ពុជា, តំណាងពីសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា, ប្រតិបត្តិករបរធនបាលដែលជាក្រុមហ៊ុនបរធនបាល និងជាបរធនបាលរូបវន្តបុគ្គលឯករាជ្យ, ប្រតិបត្តិករបរធនបាលដែលផ្ដល់សេវារក្សាសុវត្ថិភាពនិងសេវារក្សាទុក, តំណាងការិយាល័យមេធាវី និងបុគ្គលពាក់ព័ន្ធដែលផ្ដល់សេវានៅក្នុងវិស័យបរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា និងមានអ្នកចូលរួមសរុបចំនួន ១៥៨ រូប។



រូបភាពសិក្ខាសាលាផ្សព្វផ្សាយស្ដីពីការដាក់ឱ្យអនុវត្តប្រកាសស្ដីពី "ការទទួលស្គាល់ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដាវ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច ។

## កិច្ចប្រជុំ លើកទី៥ របស់គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ

នាព្រឹកថ្ងៃព្រហស្បតិ៍ ៩រោច ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២២ **ឯកឧត្តម សុខ ដាវ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាសមាជិកក្រុមប្រឹក្សានៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ក្នុងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ (**គ.ស.ហ.**) អមដោយ **កញ្ញា ឈាន សុខាវី** ប្រធាននាយកដ្ឋាន កិច្ចការគតិយុត្ត និងអធិការកិច្ចនៃ **ន.ប.ធ.** បានចូលរួមកិច្ចប្រជុំ លើកទី៥ របស់គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន **គ.ស.ហ.** និងមានការចូលរួមពី ឯកឧត្តមរដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ នៅសណ្ឋាគារសុខា រាជធានីភ្នំពេញ។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888



រូបភាពកិច្ចប្រជុំ លើកទី៥ របស់គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចក្រឡាហោម **ស ខេង** ។

## វគ្គបណ្តុះបណ្តាលស្តីពី "ការត្រួតពិនិត្យផ្ទៃក្នុង, ការរាយការណ៍ និងកាតព្វកិច្ចពាក់ព័ន្ធរបស់បុគ្គលរាយការណ៍ ក្នុងក្របខណ្ឌការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ"

នាព្រឹកថ្ងៃអង្គារ ១៤រោច ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២២ នៅអគារអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយឯកឧត្តមអគ្គនាយករង ប្រធាននាយកដ្ឋាន និងសហការី បានអញ្ជើញដឹកនាំ និងរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "ការត្រួតពិនិត្យផ្ទៃក្នុង, ការរាយការណ៍ និងកាតព្វកិច្ចពាក់ព័ន្ធរបស់បុគ្គលរាយការណ៍ ក្នុងក្របខណ្ឌការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ" ក្នុងគោលបំណងដើម្បីបញ្ជ្រាបការយល់ដឹងបន្ថែមដល់បុគ្គលរាយការណ៍ និងអ្នកតំណាងរបស់បរធនបាល ដែលជាបុគ្គលមានកាតព្វកិច្ចរាយការណ៍ក្នុងវិស័យបរធនបាលកិច្ច ក្នុងក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាបុគ្គលរាយការណ៍ក្នុងវិស័យបរធនបាលកិច្ច សរុបចំនួន ៥៨ នាក់។



រូបភាពវគ្គបណ្តុះបណ្តាលស្តីពី "ការត្រួតពិនិត្យផ្ទៃក្នុង, ការរាយការណ៍ និងកាតព្វកិច្ចពាក់ព័ន្ធរបស់បុគ្គលរាយការណ៍ ក្នុងក្របខណ្ឌការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ"។

## កិច្ចប្រជុំអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)

នារសៀលថ្ងៃព្រហស្បតិ៍ ១កើត ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយកញ្ញា **ឈាន សុខារី** ប្រធាននាយដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច និងលោក **ហាយ សុវណ្ណា** ប្រធានស្តីទីនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច បានចូលរួមកិច្ចប្រជុំអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដើម្បីពិនិត្យទៅលើរបៀបវារៈ៖ សេចក្តីព្រាងប្រកាសស្តីពី "ការកំណត់អំពីនីតិវិធី និងវិធានការគណនាប្រាក់បម្រុងបច្ចេកទេសធានារ៉ាប់រង" របស់និយ័តករធានារ៉ាប់រងកម្ពុជា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សានៃ **អ.ស.ហ.** ដោយមានការចូលរួមពីឯកឧត្តមអគ្គនាយក ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃនិយ័តករ និងអង្គភាពក្រោមឱវាទនៃ **អ.ស.ហ.** តាមរយៈកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាននៃ **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ Zoom។




រូបភាពកិច្ចប្រជុំអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)។

## ប្រជុំស្ដីពីការផ្សព្វផ្សាយអំពីគម្រោង ACSEP នៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តត្បូងឃ្មុំ

នាព្រឹកថ្ងៃសុក្រ ២កើត ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាប្រធានគ្រប់គ្រងគម្រោងស្ដីពីការលើកកម្ពស់ការប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងសុវត្ថិភាពកសិកម្ម (ACSEP) សម្រាប់សមាសភាគទី១ បានអញ្ជើញដឹកនាំកិច្ចប្រជុំស្ដីពីការផ្សព្វផ្សាយអំពីគម្រោង ACSEP នៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តត្បូងឃ្មុំ។

កិច្ចប្រជុំនេះមានគោលបំណងផ្សព្វផ្សាយអំពីគម្រោង ACSEP ឱកាស លក្ខខណ្ឌ និងការរៀបចំខ្លួន ដើម្បីទទួលបានហិរញ្ញប្បទានបន្ថែមដើម្បីពង្រីក និងពង្រឹងកសិធុរកិច្ចតាមរយៈការលើកកម្ពស់ការប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាព ដល់សហករណ៍កសិកម្ម សហគមន៍កសិធុរកិច្ច និងកសិករចិញ្ចឹមមាន់ស្រុកសក្ដានុពលក្នុងខេត្តត្បូងឃ្មុំ និងជាក្រុមក្នុងខេត្តគោលដៅមួយក្នុងចំណោមខេត្តទាំង៦ ក្នុងគម្រោង ACSEP ដែលក្នុងនោះរួមមានខេត្តព្រះវិហារ ឧត្តរមានជ័យ សៀមរាប កំពង់ធំ កំពង់ចាម និងត្បូងឃ្មុំ។

កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមដោយ លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តត្បូងឃ្មុំ ក្រុមអ្នកជំនាញការហិរញ្ញវត្ថុសម្រាប់សមាសភាគទី១ នៃគម្រោង ACSEP សមាជិកនៃអង្គភាពអនុវត្តគម្រោងសម្រាប់សមាសភាគទី១ នៃគម្រោង ACSEP សហករណ៍កសិកម្ម សហគមន៍កសិធុរកិច្ច និងកសិករចិញ្ចឹមមាន់ស្រុកសក្ដានុពលប្រមាណ **៣០ រូប** ក្នុងខេត្តត្បូងឃ្មុំ និងតំណាងគ្រឹះស្ថានហិរញ្ញវត្ថុដៃគូនៃគម្រោង ACSEP ។

កិច្ចប្រជុំនេះ បានបញ្ចប់ដោយរលូន ប្រកបដោយផ្លែផ្កា និងស្មារតីទទួលខុសត្រូវខ្ពស់។



រូបភាពកិច្ចប្រជុំស្ដីពីការផ្សព្វផ្សាយអំពីគម្រោង ACSEP នៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តត្បូងឃ្មុំ ។

## កិច្ចប្រជុំដើម្បីត្រៀមលក្ខណៈសម្រាប់ការចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ក្រុមការងារ ICRG-JG ក្នុងការដកប្រទេសកម្ពុជាចេញពីបញ្ជីប្រផេះ

នារសៀលថ្ងៃពុធ ៧កើត ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយលោក **ឆែម លាបហេង** ប្រធានការិយាល័យអធិការកិច្ច និងពង្រឹងការអនុវត្តច្បាប់, លោក **លឹម ឡេត** ប្រធានការិយាល័យគ្រប់គ្រងបរធនបាលកិច្ចសង្គមនិងបុគ្គល និងមន្ត្រីជំនាញនៃ **ន.ប.ធ.** បានចូលរួមកិច្ចប្រជុំដើម្បីត្រៀមលក្ខណៈសម្រាប់ការចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ក្រុមការងារ ICRG-JG ក្នុងការដកប្រទេសកម្ពុជាចេញពីបញ្ជីប្រផេះ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម វង្ស សីលវិជ្ជា** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**កសហវ**) និងជាប្រធានក្រុមការងារប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យនៃ **កសហវ** និងអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដោយមានការចូលរួមពី ឯកឧត្តម លោកជំទាវ លោក-លោកស្រី ដែលជាតំណាង កសហវ, គណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា, ឯកឧត្តមអគ្គនាយក ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃនិយ័តករ និងអង្គភាពក្រោមឱវាទនៃ **អ.ស.ហ.** តាមរយៈកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាននៃ **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ Zoom។




រូបភាពកិច្ចប្រជុំដើម្បីត្រៀមលក្ខណៈសម្រាប់ការចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ក្រុមការងារ ICRG-JG ក្នុងការដកប្រទេសកម្ពុជាចេញពីបញ្ជីប្រផេះ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម វង្ស សីលវិជ្ជា**។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888